# ការសម្ភាសន៍របស់អ៊ុំប្រុសកែវ វុទ្ធី

**ក៖ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិន្ទ          ខ៖ អ្នកត្រូវគេសម្ភាសន៍ឈ្មោះកែវ វុទ្ធី**

## ពត៌មានសង្ខេបរបស់អ៊ុំប្រុសកែវ វុទ្ធី

អ៊ុំប្រុសកែវ វុទ្ធីមានអាយុ៧៦ឆ្នាំហើយឆ្នាំនេះ គាត់មិនមែនជាអ្នកខេត្តសៀមរាបទេ តែគាត់បានផ្លាស់ប្តូរទីលំនៅមកពីខេត្តកណ្តាល។ គាត់មានកូន៤នាក់ ស្រី៣ ប្រុស១ ហើយគាត់ស្រីគាត់ម្នាក់កំពុងតែរស់នៅស្រុកបារាំង។ គាត់ចេះនិយាយភាសាបារាំង និងភាសាយួនបានយ៉ាងល្អ ដោយសារតែគាត់ បានរៀនសូត្រកាលពីសម័យមុន។ គាត់ក៏បានឆ្លងកាត់នូវភាពលំបាក ជូរចត់ ក្នុងសម័យដ៏ សាហាវឃោរឃៅរបស់ប៉ុល ពតផងដែរ។

ក៖ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់អ៊ុំ ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរយើងឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ុំអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាអ៊ុំណា បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍អ៊ុំចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់អ៊ុំណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodiaoralhistory.byu.edu ណាអ៊ុំ ចឹងតើអ៊ុំយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់អ៊ុំចូលទៅក្នុងវេបសាយរបស់សាលាទេអ៊ុំ?

ខ៖ ដាក់ទៅក្មួយ។

ក៖ បាទចឹងសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍នេះគឺ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិធ្លកអណ្តូង សង្កាត់ស្លរក្រាមក្រុងសៀមរាប ខេត្តសៀមរាប ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះហេង សុវណ្ណនរិន្ទ ហើយអញ្ចឹងខ្ញុំចង់ដឹងថាតើអ៊ុំមានឈ្មោះពេញឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះកែវ វុទ្ធី។

កៈ ចុះអ៊ុំមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ បាទអត់ទេ តែមួយណឹងម៉ង។

កៈ ចុះមកដល់ឆ្នាំនេះអ៊ុំមានអាយុប៉ុន្មានហើយអ៊ុំ?

ខៈ អាយុ៧០ អឺខ្ញុំកើតនៅឆ្នាំ១៩៤៥។

កៈ អញ្ចឹង៧៦ឆ្នាំហើយ?

ខៈ បាទវា៧៦ឆ្នាំហើយ ដាច់ឆ្នាំណឹងចូល៧៧ឆ្នាំ។

កៈ បាទអ៊ុំ ហើយចុះអ៊ុំចាំថ្ងៃខែឆ្នាំកំណើតជាបារាំងពេញទេអ៊ុំ?

ខៈ បាទខ្ញុំចាំខ្ញុំកើតថ្ងៃអត់ចាំទេ ខែសីហា ឆ្នាំ១៩៤៥។

កៈ ចុះអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខៈ ស្រុកកំណើតខ្ញុំនៅច្បារអំពៅ គៀនស្វាយ។

កៈ ចុះអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ម្ដាយខ្ញុំមានតែខ្ញុំមួយគត់។

កៈ អរអ៊ុំគាត់នៅក្នុងគ្រួសារ?

ខៈ បាទមានតែម្នាក់ឯងគត់។

កៈ គាត់ធ្លាប់ធ្វើអ្វីខ្លះដែរអ៊ុំកាលនៅក្មេងអ៊ុំ? ចូលចិត្តធ្វើអ្វីខ្លះអ៊ុំមានចាំទេអ៊ុំ?

ខៈ កាលពីក្មេងខ្ញុំមានតែទៅរៀនតែមួយមុខណឹង បាទទៅរៀនហើយពីក្មេងណឹង មុននឹងទៅរៀនណឹងឪពុកម្ដាយខ្ញុំក៏មិនមែនជាអ្នកមានអីទេ អ្នកក្រីក្រដែរទេគាត់ចេញពីទាហានមកគាត់នៅច្បារអំពៅណឹងណា បាទចេញពីទាហានចេញពីប៉ូលីសមក បាទមុនដំបូងគាត់នៅទាហានបានទៅនៅទាហានណឹងបានផ្លាស់ប្ដូរមកធ្វើប៉ូលីសបានមកប៉ូលីសមក ដល់នៅប៉ូលីសទៅគាត់ចូលនិវត្តន៍ទៅ គាត់ចូលនិវត្តន៍ទៅនៅច្បារអំពៅណឹងក៏គាត់ទិញផ្ទះគេមួយក្នុងច្បារអំពៅណឹង ហើយមុខរបរគាត់ម្ដាយខ្ញុំណាគាត់អ្នកបិទចង្កឹះលក់ ចង្កឹះឬស្សីយើងណឹងណាហើយ

ឪពុកខ្ញុំគាត់ធ្វើជាងផ្ទះ ដើរជួសជុលផ្ទះគេណឹងណាហើយខ្ញុំចេះតែជួយឪពុកម្ដាយទៅពេលទំនេរអត់មានធ្វើផ្ទះធ្វើអីណឹងអង្គុយបិទចឹង្កុះឲ្យគាត់ទៅហើយព្រលឹងឡើងណឹងខ្ញុំក្រោករកទិញនំប៉័ងហើយកាលពីជំនាន់ខ្ញុំរៀនណឹងរៀនមួយថ្ងៃពេញម៉ងទាំងព្រឹកទាំងល្ងាចបាទរៀនទាំងព្រឹកទាំងល្ងាច ព្រលឹមឡើងក្រោកម៉ោង៤ម៉ោងអីណឹងទៅទិញទៅយកនំប៉ុងប្រហែល២០អីណឹងរត់លក់ទៅ នំប៉ុងយើងណឹងណា។

ក៖ អរ អ៊ុំលក់នំប៉័ង?

ខ៖ បាទលក់នំប៉័ង បាទពីដើមក្មេងៗចូលចិត្តលក់នំប៉័ង ដាក់ថង់មួយមកស្ពាយរកដើរលក់ទៅនំប៉័ងៗចឹងទៅគេទិបាន បានលុយណឹងទៅរៀន លុយណឹងយកទៅរៀនទៅ ប្រវិត្តវានេះដែរយ៉ាប់ដែរខ្ញុំមិនមែនជាកូនអ្នកមានអីទេកូនអ្នកក្រីក្រដែរ។

ក៖ ចុះម្ដាយអ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ម្ដាយខ្ញុំឈ្មោះអ្នក សុំ។

ក៖ ចុះឪពុកអ៊ុំវិញ?

ខ៖ ឪពុកឈ្មោះកែវ ប៊ឹត។

ក៖ ចុះមកដល់ឥឡូវណឹងគាត់បានចែកឋានហើយតើហីអ៊ុំ?

ខ៖ គាត់ចែកឋានអស់ហើយតើតាំងពីសម័យអាពត បាទអាពតវាយកទៅសម្លាប់ហើយសម្លាប់ណឹងបងប្អូនឯងអ្នកសម្លាប់ទៀត ក្មួយគាត់ណឹងធ្វើមេភូមិ។

ក៖ អញ្ចឹង កាលដែលឪពុកម្ដាយអ៊ុំត្រូវប៉ុល ពតយកទៅសម្លាប់ណឹងអ៊ុំចាំថាឆ្នាំណាដែរទេអ៊ុំ?

ខ៖ ឆ្នាំ មើលយើងបែកអាពតវាយលុកចូលឆ្នាំ៧៥ អេ៧០ ទម្លាក់សម្ដេច៧០ អាពតវាយបែកឆ្នាំ៧៥ វាយចូលបាទវាយចូលកាលណឹងខ្ញុំនៅទីក្រុងភ្នំពេញ។

ក៖ កាលដែលឪពុកម្ដាយអ៊ុំស្លាប់ណឹងអ៊ុំនៅភ្នំពេញទេ?

ខ៖ អត់ទេកាលណឹងខ្ញុំធ្វើការនៅភ្នំពេញណាបាទនៅទីក្រុងភ្នំពេញដល់លឺស្គរគេវាយចូលអញ្ចឹងទៅអាពតវាយចូលទៅ វាយចូលទៅក៏បានអាពតគៀរចេញពីទីក្រុងភ្នំពេញឲ្យចេញមកបាទ

ឲ្យចេញមក ចេញមកវាបង្ខំឲ្យយើងចេញខ្លាចអាមេរិកកាំងទម្លាក់អីខ្លាចទម្លាក់គ្រាប់បែកអីណា វាថាឲ្យយើងចេញផុតពីទីក្រុងណឹងទៅឲ្យមកនៅជនបទមកនៅណឹងរហូតទៅឪពុកខ្ញុំស្លាប់ នៅឆ្នាំ៧៦ ឪពុកខ្ញុំអាពតវាយកទៅវាយ។

ក៖ ចុះកាលនៅសម័យប៉ុល ពតណឹងអ៊ុំមានអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ៣០ឆ្នាំជាង។

ក៖ ហើយអ៊ុំមានគ្រួសារនៅកាលណឹង?

ខ៖ កាលណឹងមានហើយខ្ញុំមានកូន១។

ក៖ បាទកូនបងគេមែនទេអ៊ុំ?

ខ៖ បាទបងគេ បងគេណឹងអាយុ៤៦ឆ្នាំហើយវាកើតឆ្នាំ៧៥ កូនខ្ញុំកើតណឹងបីទទឹងទេកូនខ្ញុំនៅ បីទទឹងទេ ប្រពន្ធខ្ញុំបីទៅហើយខ្ញុំដើរនេះដាក់រទេះអូសឥវ៉ាន់ចេញពីក្រុងភ្នំពេញមក ហើយពួក វាមានសួរថាមានធ្វើទាហានធ្វើអីទេខ្ញុំថាអត់ពួកវានិយាយថាបើធ្វើទាហានប្រាប់ត្រង់មក ពាក់ ស័ក្តិន្នាន ពាក់ស័ក្តិន្នាន អង្គការឲ្យពាក់ស័ក្តិឡើងវិញខ្ញុំថាខ្ញុំអត់មានធ្វើទាហានធ្វើអីទេខ្ញុំអ្នក ធាក់ស៊ីក្លូទេភូតវាទេ។

ក៖ បើសិនជាយើងប្រាប់?

ខ៖ បើយើងប្រាប់វាយកយើងទៅសម្លាប់ចោល យើងធ្វើការអីក៏ដោយឲ្យតែយើងធ្វើធំវាយក ទៅសម្លាប់ចោលហើយ ហើយអ្នកខ្លះគេស្រលាញ់តួនាទីខ្លះគេស្រលាញ់តួនាទីរបស់គេ ប្រាប់ ថាគេស័ក្តិ២ ស័ក្តិ៣អីឲ្យនៅមួយដុំ នៅមួយដុំគេយកទៅសម្លាប់ចោលទាំងអស់។

ក៖ ចាញ់នយោបាយគេ។

ខ៖ បាទចាញ់នយោបាយ ចាញ់នយោបាយ។

ក៖ បាទអ៊ុំ ខ្ញុំលឺចាស់ៗនិយាយថាដូចគ្នាពេលខ្លះកូនទាហានទេតែប្រាប់គេសុទ្ធតែស័ក្តិ៥។

ខ៖ បាទប្រាប់គេស័ក្តិ២ ស័ក្តិ៣ ដល់ប្រាប់គេគេឲ្យនៅមួយដុំគេយកទៅសម្លាប់ចោល។

ក៖ ចុះកាលដែលគេជម្លៀសអ៊ុំចេញណឹងគេជម្លៀសអ៊ុំទៅដាក់កន្លែងណាដែរអ៊ុំ?

ខ៖ ខ្ញុំវាឲ្យដើរមករហូតតាមផ្លូវជាតិលេខ៣ណឹងទៅតាមផ្លូវជាតិលេខ៣ ខ្ញុំទៅដល់ស្លារគូរខ្ញុំនៅត្រឹមស្លារគូរណឹងបងប្អូនខ្ញុំនៅនឹងណា បាទនៅផ្លូវជាតិលេខ៣ណឹងទៅឈប់នៅស្លារគូរណឹងទៅ បាទនៅស្លារគូរណឹងឪពុកខ្ញុំគាត់នៅដែរកាលណឹង ប៉ុន្តែគាត់ថាចង់ទៅស្រុក ទៅស្រុកខ្ញុំឃាតដែរថាពុកឪឯងកុំទៅអី ទៅមិនបានទេ ទៅគេដឹងពុកឯងធ្វើទាហាន បាទដឹងធ្វើទាហានធ្វើប៉ូលីសគេវៃហើយគេសម្លាប់ចោលហើយ គាត់អត់នេះដល់ទៅៗមែនអាពតយកទៅសម្លាប់។

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំ?

ខ៖ ម្ដាយខ្ញុំទើបតែស្លាប់។

ក៖ គាត់កាចឬក៏ស្លូតដែរ?

ខ៖ គាត់ស្លូតទេម្ដាយខ្ញុំស្លូតណាស់បាទម្ដាយខ្ញុំស្លូត ម្ដាយខ្ញុំមកស្លាប់នៅអាយុ៨៥ឆ្នាំម្ដាយខ្ញុំទើបតែមកស្លាប់សម័យយើងនេះហើយទេ បាទសម័យហ៊ុន សែនទេ គាត់នៅជាមួយខ្ញុំជាប់រហូត។

ក៖ ចុះឪពុករបស់អ៊ុំជាមនុស្សកាចឬក៏ស្លូតដែរអ៊ុំ?

ខ៖ ឪពុកខ្ញុំក៏មិនមានអ្នកកាចទេគាត់កាចតែចំពោះគេអ្នកដ៏ទៃទេ ពេលគាត់ពិសារស្រាកូនក្មេងមកលេងទ្បូរទ្បាក្បែរផ្ទះអីគាត់ស្រែកជេរមួយភូមិណឹងគាត់ជេរទាំងអស់ ចុះមនុស្សគាត់ពិសារស្រានោះ ចុះពេលគាត់សំរាន្តគាត់អីក្មេងៗលេងអីរិន មកលេងស្រែករញ៉េរញ៉ៃអីគាត់ស្រែកជេរហើយ ជេរទៅក៏ក្មេងៗរត់បាត់អស់ទៅ។

ក៖ ចុះអ៊ុំបានរៀនបទពិសោធន៍ជីវិតអ្វីខ្លះពីឪពុកម្ដាយអ៊ុំដែរអ៊ុំ?

ខ៖ ឪពុកម្ដាយខ្ញុំ ខ្ញុំអត់បានរៀនទេបានតែរៀនពីគ្រូទេ បាទបទពិសោធន៍ចេះតែជួយគាត់ទៅបិទចង្កឹះបិទអីណឹងធ្វើផ្ទះធ្វើអី ជាងផ្ទះធ្វើអីចេះយល់ការងារណឹងទៅធ្វើផ្ទះមិនបាច់សួរគេណាដល់យើងយល់តាមបទពិសោធន៍របស់គាត់មក ទៅយកមកធ្វើផ្ទះយើងផ្ទះអីណឹងអាចធ្វើបាននៅមួយ ដូចជំនាញពីឪពុកម្ដាយ។

ក៖ ចុះកាលដែលអ៊ុំរៀនណឹងអ៊ុំរៀននៅសាលាណាវិញអ៊ុំ?

ខ៖ មុខជំបូខ្ញុំរៀននៅ première នៅច្បារអំពៅបាទ première ច្បារអំពៅខ្ញុំទៅវត្តកម្សាន្តដល់ដល់ moyen 1 ខ្ញុំមកវត្តជុំ ដល់មក moyen 2 ខ្ញុំមកនេះ។

ក៖ Moyen ថ្នាក់មែនអ៊ំ?

ខ៖ ថ្នាក់ទី។

ក៖ ថ្នាក់ទី១ ទី២?

ខ៖ អឺបាទ moyen 1 មើល pour enfant préparator ថ្នាក់ទី២ណា élémentaire ថ្នាក់ទី៣ moyen 1 ថ្នាក់ទី៤ moyen 2 ថ្នាក់ទី៥ ពួក Supérieur ថ្នាក់ទី៦ ពួក Supérieur ណឹងសុទ្ធតែប្រលង certificat ប្រលង certificat ហើយប្រលងកំពង់កន្ទួតពីដើមប្រលងចូលកំពង់កន្ទួតដើម្បីទៅរៀនគ្រូធ្វើគ្រូចេញមកបង្រៀន។

ក៖ ចុះអ៊ំបានរៀនដល់ថ្នាក់ទីមួយណាដែរអ៊ំ?

ខ៖ ខ្ញុំបានរៀនដល់បាក់ឌុប បាទខ្ញុំចប់ពីណឹងទៅខ្ញុំប្រលងចូល palace ជ័យវរ្ម័នទី៧នៅជីតដួនោះ ទៅរៀននៅជីតដួណឹងជិះកង់ទៅទៀត ទៅរៀនទៅរៀនទៅខ្ញុំជាប់បាក់ឌុបឆ្នាំ១៩៦៤ បានប្រលង certificat និងគេដែរប៉ុន្តែអត់ជាប់ certificat ណឹងខ្ញុំប្រលងអត់ជាប់ខ្ញុំឌុប១ឆ្នាំ ឌុប១ឆ្នាំណឹងបានប្រលងចូលទៅជ័យវរ្ម័នទី៧ណឹងទៅរៀននៅជ័យវរ្ម័នទី៧ទៅ។

ក៖ ជ័យវរ្ម័នទី៧ណឹងសាលារៀនមែនទេអ៊ំ?

ខ៖ សាលារៀនមានដល់ lycée ដល់បាក់ឌុប។

ក៖ Lycée វិទ្យាល័យនៅចំខ្លះៗ បាទចុះអ៊ំមានចេះភាសាអ្វីផ្សេងក្រៅពីភាសាបារាំងទេអ៊ំ?

ខ៖ អត់ចេះទេ ភាសាយួនខ្ញុំចេះ។

ក៖ អរអ៊ំចេះដែរ?

ខ៖ បាទខ្ញុំចេះ។

ក៖ ចុះអ៊ំចេះវាពីណាដែរអ៊ំ?

ខ៖ ចេះ អញ្ចេះទេកាលណឹងឪពុកខ្ញុំធ្វើប៉ូលីស គាត់ទៅស៊ែបប៉ុស្តិ៍នៅនេះនៅនៅកំពង់យោល នោះ នៅអង្គួងទៀងនៅជិតព្រំប្រទល់វៀតណាមណា ដល់ហើកូនយួនកូនអីវាឧស្សាហ៍លេង ជាមួយគ្នា កាលណឹងខ្ញុំនៅតូចៗនោះចេះៗទៅចេះភាសាណឹងទៅ នៅតូចរហ័សចាំណាស់ ភាសាយួន អាចនិយាយទាក់ទងគ្នាបានយួន។

ក៖ នៅចេះដល់សព្វថ្ងៃ?

ខ៖ បាទនៅដល់សព្វថ្ងៃណឹង។

ក៖ ទាំងបារាំងទាំងយួន?

ខ៖ បាទ ទាំងបារាំងទាំងយួន។

ក៖ អូរ ល្អមែនទែនសប្បាយចិត្តបានសម្ភាសន៍អ៊ុំ ចុះអ៊ុំអាចរៀបរាប់ឬក៏ពិពណ៌នាបានទេអ៊ុំ ថាការទៅរៀនសូត្រនៅសម័យណឹងវាបែបណាដែរអ៊ុំ?

ខ៖ កាលជំនាន់ខ្ញុំរៀនណឹងរៀនទាំងពីរពេលទាំងព្រឹកទាំងល្ងាច បាទជំនាន់ខ្ញុំរៀនណឹងមាន តែ១០០ក៏បានដែរទៅរៀន១០០នឹងហើយ ក្រដាស១០០រូបនេះណឹងរូបរ៉ែកឪឡឹកណឹង បាទ ត្រូវការ ទិញទឹកកកឥឡូវទឹកកកឈូស៥០០មកហើយនំប៉័ង អរ៥កាក់មក នំប៉័ង៥កាក់គេវះនំ ប៉័ងណឹងមួយមកអស់មួយរៀលទេហើយបើយើងទិញតែ៥កាក់អត់មានលុយកាក់អាប់ហែក ក្រដាសជា២ ក្រដាសយើងណឹងណាក្រដាសណឹងយកមកដល់បត់ហើយហែកហែកវាជា២ ទៅ បត់ចឹងហើយហែកជា២ទៅអ្នកលក់យកមួយកំណាត់យើងយកមួយកំណាត់។

ក៖ គេនៅចាយដែរ?

ខ៖ ចាយហើយទុកមួយកំណាត់ណឹងយើងទុកទិញទៀត ពីដើមណឹងកាលជំនាន់ដែលខ្ញុំនៅ រៀនណឹងណា។

ក៖ ថ្មីទៀតហើយខ្ញុំបានរៀនថ្មីទៀតហើយ ខ្ញុំអត់ដែលលឺ។

ខ៖ ក្មួយអើយក្មួយស្រួលណាស់កាលជំនាន់ណឹងមានតែ១រៀល ២រៀល ណឹងអាចទៅរៀន បានក្មេងៗ។

កៈ ចុះការរៀនសូត្រនៅសាលាយ៉ាងម៉េចដែរអ៊ុំ? គ្រូទាក់ទងនិងគ្រូការបង្រៀនបង្អីណឹង ល្បីថាគ្រូនៅពីដើមកាចៗណាស់?

ខៈ អូយខ្ញុំរៀនដល់ពួក Supérieur អាថ្នាក់ទី៧ណឹង គ្រូកាចប៉ះចំគ្រូកាច ប៉ុន្តែខ្ញុំអត់ខឹងគាត់ទេ គ្រូណឹងបង្រៀនល្អណាស់ ឈ្មោះលោតាឆន លោកតាឆនផ្ទះគាត់នៅមេភ្លើងបាទគាត់បង្រៀនល្អណាស់ បង្រៀនដូចថាឲ្យចំម៉ងណាឲ្យយើងចាំ ហើយពេលសរសេតាមអានម្តងៗ dicter française បាទសរសេតាមអាន បើសិនជាយើងសរសេរខុស១ឲ្យយើងរត់បុកក្តារខៀន រត់បុកយកក្បាលបុកចឹងណា បាទយកក្បាលបុកចឹង ខុសន្មានខុស១០ដងអីបុក១០ក្បាលចឹងទៅ ។

កៈ បុកខ្លាំង?

ខៈ បាទរត់ទៅបុកក្តារខៀនណឹង។

កៈ ចុះអ៊ុំដែលរត់បុកអត់អ៊ុំ?

ខៈ ដែលតើដែលហើយកាលជំនាន់ណឹង ពីដើមកាលជំនាន់ខ្ញុំរៀនណឹងសុទ្ធតែ reaction français histoire géographie អឺ mathématiques សុទ្ធតែ français ទាំងអស់។

កៈ បាទណឹងហើយភាគច្រើនថ្នាក់គេមានទាំងរៀនគណិតជាភាសាខ្មែរគណិតជាភាសាបារាំង រូបជាសាលាខ្មែររូបជាភាសាបារាំង។

ខៈ បើប្រវិត្តសាស្ត្រអី សីលធម៌អីណឹងសុទ្ធតែភាសាបារាំងទាំងអស់កាលជំនាន់ខ្ញុំរៀន ហើយប៉ន្តែគាត់ពន្យល់រៀនស្អាតខ្ញុំនៅចាំគាត់មិនភ្លេច ហើយនិងនឹកគុណគាត់មិនភ្លេចទេ បាទគាត់ខំយកចិត្តទុកដាក់បង្រៀនយើង។

កៈ ចុះអ៊ុំបានឆ្លងកាត់ប៉ុន្មានសម័យកាលដែរអ៊ុំ?

ខៈ ខ្ញុំឆ្លងកាត់ច្រើនហើយតាំងពីសុរាម្រិត បាទសុរាម្រិតមកបានមកសីហនុ បានមកសីហនុមកមកលន់ ណុល មកលន់ ណុលមកមកប៉ុល ពត ប៉ុល ពតមកយើងហ៊ុន សែនណឹង បាទចឹង៥សម័យហើយ បាទតាំងពីនរោត្តមសុរាម្រិតណឹងណាឪពុកសម្តេចណឹងណា ឪពុកសម្តេចសីហនុខ្ញុំកើតទាន់។

កៈ ចុះក្នុងចំណោម៥ណឹងតាមគំនិតរបស់អ៊ុំ អ៊ុំចង់រស់នៅសម័យណាជាងគេដែរអ៊ុំ?

ខៈ តាមគំនិតរបស់ខ្ញុំ ខ្ញុំចង់រស់នៅសម័យហ៊ុន សែនជាង។

កៈ បាទសម័យសព្វថ្ងៃនេះមែនទេអ៊ុំ?

ខៈ បាទ ចង់រៀនៅសម័យហ៊ុន សែន ព្រោះអីសម័យហ៊ុន សែនគាត់ធ្វើល្អណាស់បានរីកចម្រើនខ្ញុំសរសើគាត់ណាស់ សម័យសីហានុគាត់រីកចម្រើនមែនតែ នៃសម័យសីហានុគាត់រីកចម្រើនណាស់ដែរប៉ុន្តែមិនសូវខ្លាំងដូចហ៊ុន សែនទេ ហ៊ុន សែនរីកចម្រើនខ្លាំងជាង។

កៈ ចុះអ៊ុំមានចាំឈ្មោះជីដូនជីតាយាយតាខាងម្ដាយបានទេអ៊ុំ?

ខៈ អត់ចាំទេក្មួយ។

កៈ ចុះខាងឪពុកចាំទេ?

ខៈ អត់ដែរខាងឪពុកខ្ញុំ។

កៈ អញ្ចឹងមានន័យថា អ៊ុំចាំត្រឹមតែឪពុកម្ដាយទេ?

ខៈ ចាំតែឪពុកម្ដាយទេ តាអីគាត់ស្លាប់ចោលអស់ដល់ធំឡើងដឹងក្ដីទៅជីតាយាយអីណឹងទាំងខាងម្ដាយខាងឪពុកអីណឹងស្លាប់ចោលអស់។

កៈ ស្ដាយមែនទែន ខ្ញុំអត់ទាន់ដែរទាន់តែយាយ។

ខៈ ខ្ញុំអត់ទាន់ទាំងអស់តាហើយនិងយាយអត់ទាន់ ទាំងខាងម្ដាយទាំងខាងឪពុក។

កៈ ចុះអីនៅសម័យប៉ុល ពតវិញអ៊ុំ ប៉ុល ពតគេដាក់ការងារអ្វីខ្លះឲ្យអ៊ុំធ្វើដែរអ៊ុំ?

ខៈ ប៉ុល ពតខ្ញុំភ័យដែរកាលណឹងខ្ញុំវាអត់ចេះស្ទូងអត់ចេះភ្ជួរ អត់ចេះភ្ជួរទេខ្ញុំថាបើសិនជាគេដាក់ឲ្យខ្ញុំទៅកងភ្ជួរណាមុខតែគេវៃចោលហើយ ចេះសំណាងដែរគុណបុណ្យវាយើងធ្វើល្អជួបតែអំពើល្អគេដាក់ទៅកងបើគេភ្ជួរយើងកាប់ជ្រុងស្រែ លើតែចបដើរកាប់ជ្រុងស្រែទៅណា។

កៈ ភ្លឺស្រែណឹងអ៊ុំ?

ខ៖ ណឹងហើយ កាប់ កាប់ ឧបមាថាគេភ្ជួរមិនដល់យើងដើរកាប់ បាទដើរកាប់ឲ្យវានេះណឹង កាប់តែអាណឹង កាប់ជ្រុងស្រែណឹងឯងហើយប្រសិនណាគេឲ្យនេះខ្ញុំថាងាបហើយ ឲ្យខ្ញុំភ្ជួរខ្ញុំមិនដឹងដឹកគោម៉េចដឹងលើនង្គ័លម៉េចទេ លើនង្គ័លផងដឹកគោផងគោមុខគោក្រោយ វរៗមុតជើងគោណឹងវាយកឯងវាយចោលទៀត រួចហើយពីណឹងមកកាប់ជ្រុងស្រែណឹងដល់ខែនេះវាឲ្យខ្ញុំកងជញ្ជូនកណ្ដាប់ ជញ្ជូនកណ្ដាប់ឲ្យគេស្ទូង ជញ្ជូនកណ្ដាប់ហើយដល់ពេលច្រូតវាឲ្យយើងរែកស្រូវ រែកស្រូវអត់ឲ្យឈប់ទេណា ដី២ ៣គីឡូវាអត់ឲ្យយើងឈប់ទេវាថាឈប់ជ្រុះគ្រាប់ស្រូវ បាទហើយម្ល៉ោះហើយស្មារខ្ញុំរែកស្មារបានទាំង២ ផ្លាស់ប្ដូរអាស្មារនេះឈឺផ្លាស់ប្ដូរមកស្មារនេះ ស្មារនេះផ្លាស់ប្ដូរមកស្មារនេះអត់ឈប់ទេបាទហើយដល់ពេលដែលយើង អាពេលវាស្ទូងវាអីណឹងឲ្យយើងដើរប្រមូលអាចម៍ អាចម៍ពួកកងចល័តណាជុះដាក់ធុងមកឲ្យដើរប្រមូលមកឲ្យស្រីៗអីណឹងគេជ្រលក់សំណាបណឹង យកនេះមកជ្រលក់អាចម៍អីណឹង ជាមួយអាចម៍គោណឹងណា អាចម៍យើងមកលាយជាមួយអាចម៍គោណឹងហើយជ្រលក់សំណាបឲ្យវានេះណាជ្រលក់ហើយគេយកទៅស្ទូងទៅដាក់ក្នុងស្រែ យកសន្ទូងណឹងមកជ្រលក់អាចម៍បាទហើយយកទៅស្ទូងទៅ។

ក៖ ប៉ុន្តែខ្ញុំលឺថាស្រែកាលណឹងធ្វើបានស្រូវច្រើនមែនទែនអ៊ុំ

ខ៖ ច្រើនមែនទែនស្រែ១ឆ្នាំឧបមាថា ភ្ជួររាស់អីហើយណឹងណាបានច្រូតហើយណឹងឲ្យកុមារកងកុមារណឹងគេមានអាកងកុមារអាយុ៤ ៥ឆ្នាំណឹងណាដើរច្រូតកាត់ជញ្ជាំងហើយ កាត់ជញ្ជាំងហើយវាភ្ជួរទៀតដាក់បាចទឹកបញ្ចូលហើយភ្ជួរធ្វើម្ដងទៀត មួយឆ្នាំធ្វើ២ ៣ដងណា បាទមួយឆ្នាំធ្វើ២ ៣ដង ភ្ជួរមិនមែនថាមួយឆ្នាំធ្វើម្ដងដូចយើងទេ យើធ្វើម្ដង ឥឡូវយើងធ្វើម្ដងវាស្រូវច្រើនហើយណា ហើយទម្រាំវាមួយឆ្នាំធ្វើ២ ៣ដងស្រូវម៉េចមួយគុណជា៣ណា។

ក៖ ខ្ញុំលឺចាស់ៗនិយាយថាស្រូវគរដូចភ្នំ។

ខ៖ បាទ ស្រូវប៉ុន្តែវាមិនឲ្យស៊ី អត់ឲ្យស៊ីទេបបរក្នុងមួយខ្ទះតែ៥កំប៉ុងអីទេ បាទ៥កំប៉ុងអស់ហើយបបរឲ្យយើងស៊ីបាទ ហើយខ្ញុំរស់ដោយសារនេះដែរ រស់ដោយសារចេះតែបោចស្លឹកឈើស្លឹកអីមកស៊ីទៅណា ហើយគ្មានអំបិលគ្មានប៊ីចេងអីទេចេះតែស្លរស៊ីទៅ បាទយកស្លឹកឈើស្លឹកអីយកស៊ី ហើយបើនិយាយពីសត្វវិញសត្វបង្គួយនៅនេះយើងមើលយើងវាញាក់មុខដាក់យើងណា ប៉ុន្តែនៅសម័យនោះអត់ហ៊ានទេរឿងមនុស្សវារត់បាត់ហើយ មនុស្សវ៉ៃស៊ីណាស៊ីខ្ញុំស៊ីតាំងពីបង្គួយតាំងពីថ្លែន ស៊ីទាំងអស់តាំងពីបង្គួយតាំងពីថ្លែនឡើង។

កៈ ចុះកាលណឹងបើសិនជាគេឃើញអ៊ុំហូបចឹង?

ខៈ ឃើញហូបអញ្ចឹងអត់បានទៀត។

កៈ អត់បានទៀត?

ខៈ វាយកអត់បានទេ។

កៈ សត្វបង្គួយសោះណឹង?

ខៈ បង្គួយ ផ្លែនក៏ដោយ បាទហើយមាន់បើយើងចិញ្ចឹមហើយអត់ឲ្យយើងស៊ីទេ បើយើស៊ីវាឃើញវាយកយើងទៅវាយចោលហើយ នឹកទៅដឹកតែគេវាយចោលហើយណាសុខចិត្តប្រថុយជីវិតហេរពេកយប់ឡើងហេរ សុទ្ធចិត្តទៅលួចដំឡូងគេដំឡូងមីយើងណឹងណា ខែភ្លៀងខ្លាំងទៅកាយយកមួយគុម្ពមួយមើម មួយគុម្ពមួយមើមៗដាក់មកដាក់មកផ្ទះវិញដុតទៅ ដុតចែកប្រពន្ធចែកកូនស៊ីទៅបាទ។

កៈ ប្រថុយជីវិតណាស់?

ខៈ បាទប្រថុយជីវិតដឹងថាទៅលួចគេគេចាប់បានងាប់ ខ្ញុំម្ដងដៃរដេកនៅផ្ទះហេរពេករទេះពោតគេដឹកមកណារទេះប្រហែលជា២០រទេះគេដឹកពោតពីយើងកោះធំនេះទៅណា ដឹកពីកោះធំទៅប្រហែលម៉ោង១២យប់ លឺសូរង៉េតង៉ត់ៗស្អីគេចេះរទេះ រទេះដឹកពោតមកហើយដឹកពោតមកទៅលួច យើងទៅសសៀរៗទៅលួចមួយរទេះលួចពោត ២ ៣លាក់ទុកទៅផុតដល់រទេះមួយមកទៀតលួចពោត២ ៣ ដល់មករទេះចុងក្រោយវាចាប់ខ្ញុំជាប់ ចាប់ជាប់ចងស្លាបចេកចឹងដាក់ខ្ញុំលើរទេះពោត ខ្ញុំថាងាប់ហើយច្បាស់ជាងាប់ហើយអត់ខានទេ ចងស្លាបសេកខ្ញុំចឹងណា ហើយខ្ញុំដៃម្ខាងខ្ញុំអង្គុយលើពោតនោះ ដៃម្ខាងទម្លាក់តាមផ្លូវរហូត វាអញងាប់ៗទៅឲ្យគេអ្នកអត់ឃ្លានបានស៊ីផង ខ្ញុំនឹកឃើញចឹងណាសុទ្ធចិត្តថាងាប់ឲ្យគេក្រោយបានស៊ីផង ទម្លាក់រហូតតាមផ្លូវទម្រាំតែដល់មន្ទីរឃុំវាទម្លាក់ពោតរហូត ទៅដល់ ទៅដល់មន្ទីរឃុំវាង មុនដល់មន្ទីរឃុំណឹងបងប្អូនឯងណឹងចាប់ខ្ញុំទៀតណាបងប្អូនឯងណឹងណាវាប្រធានកងរទេះ បាទប្រធានកងរទេះអាណឹងត្រូវជាក្មួយខាងម្ដាយខ្ញុំបានមកចាប់ ចាប់ខ្ញុំណឹង ហើយវាអត់ដឹងដែរ វាអត់ដឹងថាខ្ញុំបងប្អូនវាទេណាដល់ជួបឪពុកម្ដាយបានវាដឹង បាទដល់ហើយចឹងទៅ អាពួករទេះថាវ៉ៃវាចោលកណ្ដាលផ្លូវឲ្យហើយទៅពួកអាទេះណា វាថានេះចាំដល់មន្ទីរឃុំទៅចាំយកទៅដល់មន្ទីរឃុំ បាទទៅដល់មន្ទីរឃុំបានអាគណៈឃុំគេថាចុះអាមួយអង្គុយលើរទេះណឹងអី អាមេកង

គេថាអាណឹងលួចពោតាមផ្លូវអឺដាក់វាចុះមក ដាក់វាចុះមកស្រាយចំណងវាទៅ តោះហ្អែងឡើងលើឃ្លាំងពោតគេប៉ុណ្ណឹង ឃ្លាំងណា ឲ្យយើងឡើងលើឃ្លាំងណឹងឈរចឹងឈរចាំទទួលពោតគេហើយ២០រទេះណា ទទួលអានេះជញ្ជូនមកយើងចាក់ ជញ្ជូនមកយកចាក់នៅក្រោមទៅណាហើយដល់ហើយចឹងទៅ ដល់ចប់ជិតភ្លឺបានហើយ ជិតភ្លឺវាឲ្យពួកគាត់នៅណឹងណាស្រីៗនៅណឹង លីងពោតឲ្យខ្ញុំមួយថ្នក់បាទវាឲ្យពោតខ្ញុំមួយថ្នក់មក វាថាលើកក្រោយខ្វះខាតអីកុំលួចគេស្នើរមកដល់អង្គការមកអង្គការគេឲ្យណឹងហើយ  ហើយគេព្រលែងនោះបានដើរមកដល់ផ្ទះ មកដល់ផ្ទះមើលម៉ោងភ្លឺស្រាំងៗខ្ញុំដើរមកដល់ផ្ទះម្ដាយខ្ញុំសួរ យីអានេះមកពីណាហ្អែងខ្ញុំថាបើខ្ញុំងាប់ណឹងម៉ែអត់ដឹងផងយប់មិញខ្ញុំទៅលួចពោតគេ ទៅលួចពោតគេគេចាប់បានគេយកទៅមន្ទីរឃុំ បានអីគេដាក់ពោតមកឲ្យមួយថ្នក់ ពោតយើងណឹងណាដាក់មកឲ្យ លីងឲ្យហើយគេដាក់ពោតមកឲ្យទៀតសំណាង ខ្ញុំថាសំណាង។

កៈ ដោយសារអ៊ុំធ្វើអំពើល្អជួបតែអំពើល្អ។

ខៈ បានធ្វើតែអំពើល្អជួបតែអំពើល្អ បាទដល់ហើយម្ដាយខ្ញុំថាម៉េចបានហ្អែងទៅលួចពោតគេចឹងចុះហេរពេក បាទដល់មកចុងក្រោយទៀតខ្ញុំចេះទៅសហករណ៍ស៊ីបាយ ទៅសហករណ៍ពីដើមគេសហករណ៍ ទៅស៊ីបាយនៅសហករណ៍ណឹងទៅខ្ញុំជេរណា កន្ទួយម៉ែវាស្លរតែព្រលិតព្រលិតៗរាល់ថ្ងៃ ស៊ីចុយម៉ែវាអត់ស្រាប់តែអាឈ្លបគេលឺគេទៅប្រាប់ប្រធានភូមិ អាប្រធានភូមិគេថាឲ្យឈ្លបទៅចាប់ខ្ញុំណាអត់ជួបខ្ញុំ អត់ជួបខ្ញុំដល់ថ្ងៃក្រោយមកទៀតអាប្រធានភូមិណឹងហើយខ្ញុំស្រលាញ់គ្នាដូចបងប្អូន បាទទៅជាអញ្ចឹងទៅវិញទៅ បាទស្រលាញ់គ្នាដូចបងប្អូនអញ្ចឹង បាទហើយពេលណាមួយនោះខ្ញុំវាគិតឃើញដែរណាអាប្រធានភូមិណឹងណាគេអើយធ្វើបដិវត្តន៍កន្ទួយម៉ែវាអីព្រលឹមឡើងរកតែគុយទាវស៊ីមិនបានអាប្រធានភូមិណឹង ខ្ញុំថាគេនេះនិយាយមែនឬនិយាយមែនចេះតែចាំស្ដាប់ទៅយើងអត់ហ៊ានឆ្លើយឆ្លងជាមួយវាទេណា វាថាអញនៅដើមផាក់តែស៊ីក្លូអញព្រលឹមឡើងអញស៊ីគុយទាវហើយ មកដល់ធ្វើបដិវត្តន៍យូរៗទៅរកតែបាយកកស៊ីមិនបាន ខ្ញុំថាដល់មែនទែនបានដឹងចិត្តវា អរអានេះស្អប់មែនអានេះស្អប់ដែរប៉ុន្តែវាធ្វើម៉េចដល់ក្រោយពួកណឹងមកជួបខ្ញុំទាំងអស់ ខ្ញុំមកនៅគ្រប់គ្រងកុមារកំព្រារទី៣ខ្ញុំហៅ អាពួកប្រធានភូមិពីណឹងមកណាមកជួបខ្ញុំវាធ្វើជាងវាធ្វើជាងតម្លើងគ្រែ តម្លើងគ្រែរសឺណឹងឲ្យ World Vision ណាគ្រែ World Vision ឲ្យមកតម្លើងកន្លែងខ្ញុំឲ្យណឹង ជួបគ្នាណឹងអុញបងនៅនេះតើវាសួរខ្ញុំណា អញនៅនេះហាស យើងចេះតែសំណាងខ្ញុំត្រូវងាប់២ ៣ដង ណឹងណាប៉ុន្តែអត់អីណា អាលួចពោតគេណឹងម្ដងគេជេរនៅក្នុងសហករណ៍ណឹងម្ដងត្រូវគេសម្លាប់ហើយអាគេយកទៅសម្លាប់ហើយណាអាប្រធានភូមិណឹងអត់ឲ្យទៅទេគេចែកសាច់គោហើយ

សាច់ជ្រូកមួយគីឡូម្នាក់ ខ្ញុំថាចុងចុះហ្អែងចែកអញផងហាសអាប្រធានភូមិនោះហ្អែងមិនចែកអញផង បងឯងអត់ទេបងឯងចាំនេះទៅចាំលើកក្រោយណឹងហើយហើយគេចែកឲ្យមួយឡូៗម្នាក់គេយកទៅសម្លាប់គេឲ្យឡើងរទេះគេយកទៅ ជញ្ជូនទៅទាំងអស់ទាំងសំប៉ុកៗមួយគ្រួសារៗគេចែកឲ្យស៊ី បាទចែកឲ្យស៊ីហើយយកទៅសម្លាប់ចោល។

ក៖ ចុះអ៊ុំដឹងថាមូលហេតុអីបានជាគេយកទៅសម្លាប់ចោលដោយសារគាត់?

ខ៖ អានេះគេស្រាវជ្រាវ គេស្រាវជ្រាវដឹងប្រវិត្តពីមុនមកអីៗណាបាទ ដឹងប្រវិត្តមកថាធ្វើៗណាគេស្រាវជ្រាវណាតាមការអាជម្លៀសដូចគ្នាណឹងចេះតែចាក់រុកគ្នាទៅ អ្នកជម្លៀសដូចគ្នាណឹងណាវាមានទំនាស់គ្នាវាចេះតែចាក់រុកគ្នាទៅអានេះធ្វើនេះតិចទៅហើយធ្លាប់ស្គាល់គ្នាអានេះធ្វើនេះវាដឹងដោយសារអញ្ចឹងទេវាទៅស្រាវជ្រាវឯណាដឹង តែគ្នាឯងណឹងបាទ។

ក៖ បាទណឹងហើយអ៊ុំដែលបានចែកចាយពីសម័យប៉ុល ពត ចុះតាំងពីក្មេងរហូតមកដល់ពេលនេះ តើអ៊ុំធ្លាប់ប្រកបការងារអ្វីខ្លះដែរដើម្បីចិញ្ចឹមជីវិតអ៊ុំ?

ខ៖ បាទពីមុនមកកាលពីសម័យសម្តេចសីហានុខ្ញុំធ្វើប៉ូលីស បងខ្ញុំមួយពាក់ស័ក្តិ៥លោកនួន ថៃឥឡូវគាត់ លោកនួន ថៃណឹងប៉ូលីសនៅខាងខេត្តតាកែវគាត់យកខ្ញុំធ្វើប៉ូលីសបាទ យកទៅធ្វើប៉ូលីសខ្ញុំទៅប៉ូលីសគេបញ្ជូនទៅនេះនោះ បញ្ជូនទៅអឺរតនអឺ។

ក៖ មណ្ឌលគីរី?

ខ៖ មិនមែនទេទៅស្ទឹគេ?

ក៖ ព្រះវិហារ?

ខ៖ អត់ទេ អត់ទេ ឆ្ងាយជាងគេរតនៈគីរី បាទទៅនៅណឹងជាមួយពួកភ្នង់ពួកអីណឹង កាលណឹងពួកភ្នង់គេធ្វើនេះ បាតុកម្មអីណាសម្លាប់ប៉ូលីសសម្លាប់អីពួក គេនាំពួកខ្ញុំទៅ៥នាក់ផ្លាស់ពីភ្នំពេញទៅ ៥នាក់នោះទៅនៅឈរជើងនៅរតនៈគីរី បាទទៅពីដើម ពីដើមទៅពីភ្នំពេញទៅជិះឡានម៉ោង៩យប់បានដល់ពីភ្នំពេញទៅ ទៅពីនេះម៉ោង៧យប់ទៅដល់ក្រចេះភ្លឺបាទដល់ក្រចេះភ្លឺទៅរហូតដល់រតនៈគីរីម៉ោង៩យប់។

ក៖ ចឹងមានន័យថា២៤ម៉ោង?

ខ៖ បាទ ផ្លូវវាក្រឡិកក្រឡុកៗតាមផ្លូវទៅពិបាកហើយចឹងមកអាពតវ៉ៃចូល វ៉ៃចូលពួកខ្ញុំជាប់នៅរតនៈគីរីបានអាមេរិកកាំងយកកប៉ាល់ហោះរទៅដឹក ដឹកចុះនៅឡាំសឹងនោះយកទៅដាក់នៅបន្ទាយឡាំសឹងកន្លែងហ្វឹកហ្វឺនទ័ពណាបាទយកដាក់ណឹង យកដាក់ណឹងហើយទទួលទៅនៅណឹងជិត២ខែបានវាបញ្ជូនមកខ្មែរយើងវិញវាអញ្ចេះវាអត់មានជើងកប៉ាល់ហោះរព្រោះអីកប៉ាល់ហោះរអាមេរិកកាំងវាជាប់ដឹកសម្ភារៈសឹកណាជាប់ដឹកសម្ភារៈ ដល់នៅជាប់ដឹកសម្ភារៈនៅណឹងរហូតដល់២ ៣ខែនោះ។

ក៖ ប្រវិត្តរបស់អ៊ុំច្រើនមែនទែនចឹង ទៅដល់ណាណីណោះអ៊ុំ។

ខ៖ បាទដល់ណាណីនោះ។

ក៖ អញ្ចឹងអ៊ុំធ្លាប់ធ្វើប៉ូលី?

ខ៖ ធ្វើប៉ូលីសដល់សម័យវ៉ែន ម៉ន ទម្លាក់សម្ដេចណឹងមកគេឲ្យ verser មកទាហានវិញទាំងអស់ប៉ូលីស។

ក៖ Verser ណឹង

ខ៖ ផ្លាស់។

ក៖ ផ្លាស់ប្ដូរ?

ខ៖ ផ្លាស់ប្ដូរមកធ្វើទាហានវិញ មកទាហានវិញខ្ញុំនាំទ័ពទៅរៀនៅឡាំសឹង។

ក៖ ឡាំសឹងណឹងនៅខេត្តណាដែរអ៊ុំ?

ខ៖ ឡាំសឹងខេត្តអីគេនៅស្រុកយួនគេហៅឡាំសឹង បាទទៅរៀននៅឡាំសឹងហើយ នាំទ័ពទៅរៀននៅឡុងហៃទៀត ឡុងហៃជិតព្រំប្រទល់ដែនវៀតណាមខាងជើងណា បាទទៅរៀនណឹងហើយទៅរៀននាំ ២ ៣នោះខ្ញុំនាំកូនទាហានទៅរៀនណឹង បាទទៅរៀនចំណេះវិជ្ជាខាងយុទ្ធសាស្ត្រពីវៀតណាមមក ហើយ TOD អាមេរិកកាំងហើយ TOD របស់យួនខុសគ្នា យួនមួយ Group មានតែ៨នាក់ទេ បើរបស់អាមេរិកកាំងមាន១២នាក់។

ក៖ TOD ណឹងអីគេអ៊ុំ?

ខ៖ TOD ណឹងអាការរៀបចំជា Section ណាជាក្រុមណឹងណា។

ក៖ អញ្ចឹងអ៊ុំចេះយុទ្ធសាស្រ្តទាហានហើយចឹង?

ខ៖ បាទចេះ ខ្ញុំអារឿងនេះខ្ញុំមើល boussole ច្បាស់ដែរណឹងណា boussole ។

ក៖ Boussole ណឹងអីគេអ៊ុំ?

ខ៖ Boussole ណឹងអានេះត្រីវិស័យ យើងមើលអាត្រីវិស័យណឹងឧទាហរណ៍ថា ខ្មាំងផ្លោងចេញពីកន្លែងណឹងមក យើងឃើញអណ្តាតភ្លើងភ្លាមចុច boussole ភ្លាម ប៉ុន្មានណាយើង telephone ទៅខាងនោះហ្អែងមានឃើញគេផ្លោងទេ ថាឃើញដែរហ្អែងចុច boussole ទៅឃើញប៉ុន្មានណាឧទាហរណ៍វាឃើញប៉ុន្មានយើងយកមកដាក់ boussole ចឹងមក ដាក់ក្នុងផែនទីណាឃើញប៉ុន្មានដាក់ boussole ចឹងមក ហើយគូរចឹងទៅកាលណាជួបគ្នា អាកន្លែងណឹងឯងដែលខ្មាំងផ្លោង។

ក៖ ហើយអញ្ចឹងអ៊ុំអាចផ្លោងកាំភ្លើងធំទៅវិញបាន ដឹងបានខ្មាំងនៅណឹង។

ខ៖ បាទអាចផ្លោងបាន ពីណឹងទៅមើលក្នុងផែនទីមិននៅប៉ុន្មានគីឡូយើងអាចផ្លោងឲ្យចំណឹងម៉ង យើងអាខាងនេះក៏ឃើញខាងនេះឃើញដាក់ boussole ចឹងទៅរកទៅចឹងទៅ ដល់ចំចំណុចជួបគ្នា អាចំណុចជួបគ្នាណឹងជាចំណុចខ្មាំងផ្លោងហើយ ហើយយើងមើលក្នុងនេះផែនទីប៉ុន្មានគីឡូៗដឹងហើយ។

ក៖ អូ អ៊ុំមានបទពិសោធន៍ច្រើនមែនទែន។

ខ៖ បាទ បទពិសោធន៍ច្រើនខ្ញុំ។

ក៖ ចុះភរិយារបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ភរិយាខ្ញុំហ្អេ?

ក៖ បាទ។

ខ៖ ភរិយាច្រើនណាស់ខ្ញុំ ៤ ៥ណោះ ភរិយាយមុនស្លាប់ ឈ្មោះឡាំង ស៊ីម ស្លាប់ បាទប្រពន្ធខ្ញុំស្លាប់នៅសម័យលន់ ណុល ហើយមកក្រោយទៀតមកប្រពន្ធមួយទៀតឈ្មោះអូន ផ្ទះនៅ

អរិយក្សត្រនេះ បាទក្រោយណឹងមកលែងគ្នាទៅ ចេញពីអាពតមកគេមានប្រុសថ្មីបាទទៅស្រលាញតួល្ខោន ខ្ញុំក៏ហៅអាតួល្ខោនណឹងមកឲ្យទៅ ឲ្យទៅបើថាបានស្រលាញ់ហើយ ទៅ ទៅយកទៅ ដល់មកចឹងមកខ្ញុំបានប្រពន្ធមួយទៀត ប្រពន្ធមួយទៀតណឹងឈ្មោះវាអីនេះ ប្រពន្ធមេម៉ាយទេកូនគេពកូនគេនៅតូចៗមេម៉ាយ ប្រពន្ធមេប៉ូលីសណាមេប៉ូលីសនៅអូរបែកក្អមយើងណឹង បាទមកស្រលាញ់ខ្ញុំស្រលាញ់ខ្ញុំទៅបានយកគ្នាណឹងបានប៉ុន្មានជិត១០ដែរ លេងបៀរពេកចូលតែកាស៊ីណូ ហើយបានលែងពីណឹងទៅទៀតមកក្រោយទៀត មួយទៀតនៅស្វាយលើនាគ ដល់ជួបមីមួយនៅស្វាយលើណឹងអូ!ផឹកមិនបាច់ទេផឹកផ្តាំចាស់ ផឹកមានលុយឲ្យប៉ុន្មានក៏អត់សល់ដែរ ផឹកអស់ហើយទើត្រឹមណឹង ហើយបើស្រីកំប៉ិកកំប៉ុកណឹងច្រើនណាស់។

ក៖ ចុះភរិយាសព្វថ្ងៃណឹងឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ភរិយាសព្វថ្ងៃណឹងឈ្មោះជិន យឺន អាយុ៥៦ឆ្នាំ។

ក៖ សព្វថ្ងៃនេះណា?

ខ៖ បាទ ពីដើមធ្វើការនៅអង្គរ shopping នេះដល់មកអាស្រុក COVID ចឹងទៅថៅកែគេឲ្យផ្អាកវាអត់មានភ្ញៀវណា ផ្អាកពីខែមួយមកនៅតែផ្ទះ។

ក៖ ចុះអ៊ុំហេតុអ្វីក៏ជួបគ្នាជាមួយគាត់ដែរអ៊ុំ?

ខ៖ ចុងក្រោយគេណឹងគេធ្វើការនៅអា shopping ណឹងហើយពួក shopping ណឹងពួកអ្នកលក់ដូរណឹងណាអ្នកលក់ដូរក្នុងណឹងគេការ ការហៅវាទៅជួយបម្រើតុណា ហើយខ្ញុំក៏គេអាអ្នកណឹងស្គាល់គ្នាឪពុកម្តាយខាងគេណឹងណាហៅខ្ញុំទៅស៊ីការ ទៅស៊ីការកូនខ្ញុំក៏ទៅស៊ីដែរហៅទាំងអស់កូនខ្ញុំ២គ្រួសារហៅទៅហើយខ្ញុំក៏ទៅដែរទៅមួយគ្នាណឹងដែរទៅមួយតុ អង្គុយមួយតុចឹងទៅឃើញប្រពន្ធខ្ញុំណឹងរាំស្អាតអាកូនៗខ្ញុំណឹងណាឃើញប្រពន្ធខ្ញុំណឹងរាំស្អាតក៏ហៅមកឲ្យចូលរួមតុជាមួយគេថារាំជាមួយប៉ាខ្ញុំតិចទៅ ដល់រាំចឹងទៅទាក់ទងគ្នារហូតបានមក។

ក៖ អ៊ុំមន្តស្នេហ៍ដល់ហើយ?

ខ៖ ពីដើមស្រីៗមើលមុខខ្ញុំចំអត់បាន ឲ្យតែមើលមុខចំដឹងតែបានម៉ង ហើយខ្ញុំដើរលេងពីដើមនៅកំលោះណាពេលសមាជម្តងៗគេលេងនេះហើយណាអងកេសគេលេងនៅកន្លែងមែនៗ

ទៅណា ខ្ញុំដើរជាមួយពួកម៉ាក់ខ្ញុំស្អាតណាស់អានោះដូចជាយុទ្ធ ថនបេះបិត សុទ្ធតែស្អាតៗ វាអត់ស្រលាញ់ពួកនោះមកស្រលាញ់ខ្ញុំវិញស្រីៗ។

កៈ អ៊ុំសម្រស់ជាងទេបានមកស្រលាញ់អ៊ុំ?

ខៈ អត់ទេ សម្រស់អានោះស្អាតណាស់ដូចជាយុទ្ធ ថនចឹងពួកម៉ាក់ខ្ញុំ។

កៈ ចុះតាំងពីក្មេងមកណាអ៊ុំ អ៊ុំធ្លាប់មានក្តីស្រម៉ៃថាពេលធំឡើងចង់ធ្វើអ្វីទេអ៊ុំ?

ខៈ អត់មានថាចង់ធ្វើអីទេ អត់មានចង់បានធ្វើអីទេពីក្មេងមក។

កៈ ចង់និយាយថាពេលខ្លះធំឡើងទៅចង់ធ្វើជាគ្រូពេទ្យ ចង់ធ្វើទាហាន ចង់ធ្វើអ្នកបើកយន្តហោះអីចឹងណាអ៊ុំ?

ខៈ អត់ អត់មានក្តីស្រម៉ៃអីចឹងទេ បាទទៅតាមសមាជីវទៅ ទៅតាមនេះទៅបាទ ខ្ញុំកាលនេះចូលរៀនពេទ្យបានប៉ុន្មានខ្ញុំអេខ្លាច ខ្លាចឈប់រៀនបណ្តោយទៅ។

កៈ ចុះតាំងពីក្មេងមកដល់ពេលនេះអ៊ុំចូលចិត្តពិសារម្ហូបអ្វីជាងគេដែរអ៊ុំ?

ខៈ ខ្ញុំចូលចិត្តសម្លរម្ជូរបាទ បើសម្លរម្ជូរខ្ញុំហូបបាយបានច្រើន។

កៈ ចុះអ៊ុំចូលចិត្តស្តាប់ចម្រៀងចំអីទេអ៊ុំកាលពីក្មេង?

ខៈ ពីក្មេងចូលចិត្តណាស់ស្តាប់ចម្រៀង បទពីសង្គមចាស់ស្អីក៏ចាំដែរ ឲ្យតែបទពីសង្គមចាស់ប៉ុន្តែច្រៀងមិនពិរោះដូចគេ។

កៈ ចុះអ៊ុំចេះលេងឧបករណ៍តន្ត្រីខ្មែរអីទេអ៊ុំ?

ខៈ បាទអត់ទេ ពួកម៉ាក់ខ្ញុំមួយអាផាន់ ពីដើមវាលេងហ្គីតាមានតែវាទេពូកែជាងគេរៀនជាមួយខ្ញុំដែរអាផាន់ណឹង អាផាន់ណឹងគេយកទៅវាលេងហ្គីតាល្អណាស់ថ្លៃ ហើយខ្ញុំពីដើមកាលខ្ញុំនៅកម្លោះណាសុទ្ធតែខាងភ្លេងទាំងអស់ អាស្វាយសុគីលអាស្វាយអីណឹងសុទ្ធតែពួកម៉ាក់ខ្ញុំ ភូម ភូន ស្វាយសរនេះ បាទប្អូនស្វាយសរស្គាល់អត់?

កៈ អត់ផងអ៊ុំ។

ខ៖ ស្វាយសរយើងមើលអានេះណឹង ស្វាយសរពីដើមគាត់លេងភ្លេងក្នុងវាំង បាទលេងភ្លេងក្នុងវាំងសម្រាប់ស្ដេច បាទហើយប្អូនវាឈ្មោះអាស្វាយសុគីល ហើយអាស្វាយសុគីលអាស្វាយអីណឹងសុទ្ធតែពួកម៉ាក់ទាំងអស់ ពួកភ្លេងសុទ្ធតែពួកម៉ាក់ខ្ញុំទាំងអស់ ប៉ុន្តែខ្លួនឯងវាអត់ចេះអីឲ្យតែពេលពួកម៉ាក់លេងទៅជាមួយគេហើយ ទៅហើយខ្ញុំពូកែរាំ រាំពូកែណាស់ឲ្យតែពួកវាលេងភ្លេងខ្ញុំទៅហើយទៅរាំហើយ ហើយពីដើមរាំកាច់គ្នាចេះ ឧបមាថារាំកាច់គ្នាមើលតែអានេះរាំចឹងៗមកយើងចេញអាក្បាច់កាច់បណ្ដោយ ណឹងហើយម៉ាឌីស្សូនអីវិនវារាំអាម៉ាឌីស្សូនទះដៃយើងចេញអាម៉ាឌីស្សូនផ្សេងទៅ យើងម៉ាឌីស្សូនសុទ្ធតែពរ សឺណូអីវិនទៅ ណឹងហើយម៉ាឌីស្សូនដឹរ៉ាន់ឈើ។

ក៖ ក្បាច់ចេះម៉េសអ៊ុំខ្ញុំអត់ដែលលឺសោះ។

ខ៖ ច្រើនណាស់ម៉ាឌីស្សូន ក្មួយដែលឃើញទេកាលពួកកងទ័ពព្រះវិហារនេះ ធ្វើនេះពេលបុណ្យម្ដងៗពួកណឹងរាំម៉ាឌីស្សូនជាក្រុមស្អាតណាស់ណា បាទខ្ញុំរាំចឹងដូចពួកណឹងរាំចឹងបាទរាំស្អាតណាស់ពួកណឹង ហើយ ឆាច់ៗឆារ រ៉ាល់អីវិនណឹងចេះមួយចប់។

ក៖ ចុះមិត្តភិក្ដដែលស្និតស្នាលធំធាត់ជាមួយគ្នាណឹងមានប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ មិត្តភិក្ដខ្ញុំមានដែរតែបែកអស់ហើយខ្ញុំ មានតាំងពីកូន ឥន្ទ តាំ កូនឥន្ទ តាំហើយក៏អាសុងស័ក្ដអាចំណាណយើងនេះវាទៅនៅស្រុកបារាំងអស់ហើយ ហើយកូនអី ឥន្ទ តាំណឹងទៅនៅស្រុកបារាំងអស់ហើយអាតយ។

ក៖ ម៉េចឈ្មោះអីដែរអ៊ុំ? កូនអ្នកណាគេដែរអ៊ុំ?

ខ៖ សុង ស័ក្ដិតែឈ្មោះវាអាចំណាណអាណឹងវាទៅនៅបាំរាំងដែរបាទទៅនៅបារាំងអស់ហើយ ហើយពួកម៉ាក់ខ្ញុំដែររៀនជាមួយគ្នាវានៅបារាំងច្រើនដែរតើ បាទគេទៅនៅបារាំង។

ក៖ បារាំងឡើងហូរដូចទឹកអស់ហើយ។

ខ៖ បាទ រៀនជាមួយគ្នាណឹងឈ្មោះវាអាប៉េង ហោង អាណឹងក៏នៅបារាំងដែរហើយវាមកបើកធនាគារនៅភ្នំពេញយើងណឹងដែរ មកជួបខ្ញុំអីវិនវានៅស្គាល់តើពេលជួបខ្ញុំ ឲ្យលុយខ្ញុំចាយ។

ក៖ ចុះអ៊ុំមានបងប្អូនដែលរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់ទេខ្ញុំមានតែកូនមួយទេនៅបារាំង។

ក៖ ចុះគាត់ទៅនៅបារាំងណឹងទៅនៅដោយ?

ខ៖ ប្ដីវានាំទៅ ទៅជិត២០ហើយ កូនវាអាយុ១៧ឆ្នាំហើយទៅតាំងពីកូនតូច១៧ឆ្នាំ ១៨ឆ្នាំហើយវាទៅនៅបារាំង។

ក៖ ចុះកាលពីនៅក្មេងអ៊ុំធ្លាប់បានអឺបានលេងល្បែងកំសាន្តអ្វីខ្លះដែរខែចូលឆ្នាំ?

ខ៖ ខែចូលឆ្នាហី?

ក៖ បាទ។

ខ៖ ខែចូលឆ្នាំលេងដូចយើងសម័យនេះដែរណឹងណា លេងលាក់កន្សែង ទាញព្រាត់អីចឹងទៅបាទ ហើយចាំកូនខ្លែងអីចឹងទៅ រាំអីទៅ ច្រើនបែបតែខ្ញុំចូលចិត្តតែរាំ ចូលចិត្តតែរាំ។

ក៖ ចុះហើយអ៊ុំមានកូន និងចៅប៉ុន្មាននាក់ដែរសព្វថ្ងៃនេះ?

ខ៖ ខ្ញុំកូនចៅ៤នាក់ ១នាក់នៅភ្នំពេញ ២នាក់នៅសៀមរាប ១នាក់ទៀតនៅបារាំង ទាំងអស់ណឹងមានតែប្រុសតែ១ទេកូន ស្រី៣។

ក៖ អញ្ចឹងមកដល់ចុងបញ្ចប់នេះអ៊ុំមានអ្វីចង់ផ្ដាំផ្ញើរទៅកាន់ពួកគាត់ទេអ៊ុំ? ថាត្រូវរស់នៅបែបណា? ថាធ្វើជាមនុស្សបែបណាក្នុងសង្គមដែរ? ចាត់ទុកថានេះជាកេរ្តិ៍ដំណែលទុកឲ្យគាត់ចឹងណាអ៊ុំ អ៊ុំចង់ផ្ដាំអ្វីទៅគាត់ដែរ?

ខ៖ ជាចុងក្រោយនេះខ្ញុំសូមផ្ដាំផ្ញើរដល់ចៅៗទាំងអស់ណាដែលបានកើតមកក្នុងសម័យនេះបាទ ព្រោះអីសម័យនេះជាសម័យមួយដ៏ជឿនលឿន ខ្ញុំមិនដែលស្មើចទេកាលខ្ញុំនៅរៀនណាខ្ញុំនៅរៀនក្រោកឡើងទន្ទេញមេរៀន ហើយស្រាប់តែដល់សម័យនេះឃើញក្មេងៗពូកែណាស់ពូកែម៉ងពូកែ ពូកែខាង អាយុក្មេងប៉ុន្មានក៏ចេះប្រើទូរស័ព្ទ បាទហើយអ្វីក៏ឆាប់ចាប់យល់ដែរក្មេងសម័យនេះពូកែណាស់បាទ ប៉ុន្តែកុំភ្លេចកាលសម័យអាពតណាជួបប្រទះការលំបាកខ្លាំងណាស់ បាទក្មួយៗមិនទាន់ជួបប្រទះទេសម័យប៉ុល ពតបាទ ជួបប្រទះការលំបាកវេទនាខ្លាំងបាទសុំអស់ហើយ។

ក៖ បាទអ៊ុំ ខ្ញុំអរគុណអ៊ុំច្រើនអ៊ុំដែលបានចំណាយពេលសម្ភាសន៍ជាមួយខ្ញុំអ៊ុំណា ហើយខ្ញុំសូមជូនពរឲ្យអ៊ុំមានសុខភាពល្អ មានសំណាងល្អ និងមានសុវត្ថិភាពណាអ៊ុំណា៕